**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើសម្បទានរាជាយស្ម័យយានកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ១០ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥

- បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រម លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់គម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតក្របខ័ណ្ឌគតិយុត្តិ ក្នុងការធ្វើសម្បទានរាជាយស្ម័យយានកម្ពុជា និងបង្កើតនីតិវិធី សម្រាប់ធ្វើការអនុម័ត និងការគ្រប់គ្រងកិច្ចព្រមព្រៀងសម្បទាន។

**មាត្រា ២.-**

ពាក្យបច្ចេកទេស ដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ :

**កិច្ចព្រមព្រៀងសម្បទាន** : សំដៅដល់កិច្ចព្រមព្រៀងត្រូវចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា និងសម្បទានិក ដែលបង្កើតសិទ្ធិ និងកាតព្វកិច្ចនៃភាគីនិមួយៗ និងអាណត្តិ ដែលបានព្រមព្រៀងសម្រាប់ការធ្វើអាជីវកម្ម ការថែទាំ ការជួសជុល និងការអភិវឌ្ឍន៍រាជាយស្ម័យយានកម្ពុជា មុន និងក្រោយការស្តារឡើងវិញ។

**សម្បទានិក** : សំដៅដល់ក្រុមហ៊ុនឯកជន ដែលបានចុះបញ្ជីក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលជាភាគីមួយទទួលបានកិច្ចព្រមព្រៀងសម្បទាន។

**វិសោធនកម្មលើកិច្ចព្រមព្រៀងសម្បទាន** ៖ សំដៅដល់ការកែសម្រួលកិច្ចព្រមព្រៀងសម្បទាននាពេលអនាគត ដែលធ្វើឱ្យប៉ះពាល់ដល់ចំណូលរបស់រាជរដ្ឋាភិបាលពីការធ្វើសម្បទាន ឬការបង្កើន ឬការបន្ថយទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងសម្បទាន ។

**មាត្រា ៣.-**

សម្បទានិកមានសិទ្ធិក្នុងការធ្វើអាជីវកម្ម ការថែទាំ ការជួសជុល និងការអភិវឌ្ឍន៍រាជាយស្ម័យយានកម្ពុជាមុន និងក្រោយការស្តារឡើងវិញ ។

អាណត្តិ និងល័ក្ខខ័ណ្ឌនៃការធ្វើសម្បទានត្រូវចែងនៅក្នុងកិច្ចព្រមព្រៀងសម្បទាន ។

## ជំពូកទី ២
## នីតិវិធីសម្រាប់អនុម័តកិច្ចព្រមព្រៀងសម្បទាន

**មាត្រា ៤.-**

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវជ្រើសរើសសម្បទានិក តាមរយៈការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ហើយត្រូវចរចាលើអាណត្តិ និងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងសម្បទានជាមួយសម្បទានិក ដែលបានជ្រើសរើសរួចហើយ ។

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវរៀបចំឯកសារដេញថ្លៃ សេចក្តីព្រាងកិច្ចព្រមព្រៀងសម្បទាន និងឯកសារពាក់ព័ន្ធផ្សេងទៀត ហើយត្រូវដាក់ឯកសារទាំងនោះជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច មុនធ្វើការផ្សព្វផ្សាយឯកសារដេញថ្លៃ ។

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវដាក់ស្នើកិច្ចព្រមព្រៀងសម្បទាន ដែលបានចរចារួចហើយ ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យរួចដាក់ស្នើសុំការសម្រេចពីគណៈកម្មាធិការជាតិគម្រោងផ្លូវដែកសឹង្ហបុរី-គុនមីញ មុននឹងដាក់ជូនរាជរដ្ឋាភិបាលអនុម័តជាចុងក្រោយ ។

**មាត្រា ៥.-**

តាមការប្រទានសិទ្ធិពីរាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្បទាន ។

## ជំពូកទី ៣
## ការគ្រប់គ្រងកិច្ចព្រមព្រៀងសម្បទាន

**មាត្រា ៦.-**

ក្នុងអាណត្តិនៃកិច្ចព្រមព្រៀងសម្បទាន គណៈកម្មាធិការគ្រប់គ្រងសម្បទានត្រូវពិនិត្យ និងតាមដានការអនុវត្តនីកាតព្វកិច្ចរបស់សម្បទានិក ដែលមានចែងក្នុងកិច្ចព្រមព្រៀងសម្បទាន។ គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវរាយការណ៍រៀងរាល់ឆមាសជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៧.-**

ក្នុងករណីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងសម្បទាន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើសុំការសម្រេចជាមុនពីរាជរដ្ឋាភិបាល។

**មាត្រា ៨.-**

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវមានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការការងាររបស់ខ្លួន ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ គណៈកម្មាធិការនេះមានសិទ្ធិទទួលការឧបត្ថម្ភគាំទ្រថវិកាពីប្រភពផ្សេងៗទៀតបាន។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៩.-**

ក្រោយពីអនុក្រឹត្យនេះចូលជាធរមាន ក្រុមការងារគ្រប់គ្រងសម្បទាន ដែលបានបង្កើតឡើងក្រោមអនុក្រឹត្យ លេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ត្រូវប្តូរឈ្មោះទៅជាគណៈកម្មាធិការគ្រប់គ្រងសម្បទានវិញ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

Chanthol Sun

ស៊ុន ចាន់ថុល

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ